សម្រាប់ការគ្រប់គ្រងប្រើប្រាស់ ... ត្រូវកែសម្រួលតាមអនុក្រឹត្យ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទត្រូវបាន កែសម្រួលតាមអនុក្រឹត្យតាមសំណើរបស់តំណាងក្រសួង ។

មាត្រាទី ៩ . មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ មានសមត្ថកិច្ចស្រាវជ្រាវរៀបចំគម្រោងអភិវឌ្ឍន៍ជនបទជាតិនៃកម្ពុជាដែលមានលក្ខណៈ ក្នុងការបង្កើតជនបទ ឬការបង្កើត ជាមូលនិធិជាតិ មូលនិធិអភិវឌ្ឍន៍ ឬមូលនិធិផ្សេងៗ ដើម្បីសម្រេចគោលនយោបាយរបស់ខ្លួន ។

មាត្រាទី ១០ . មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ ត្រូវបានទទួលស្គាល់ជានីតិបុគ្គល មានស្វ័យភាពហិរញ្ញវត្ថុ ... ដែលមានចែងក្នុងមាត្រាទី៣ នៃច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃ ... ជាតិនៃកម្ពុជា ។

មាត្រាទី ១១ . ធនធានមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទមកពីថវិកា ... ជំនួយពីអង្គការ និង ... និង ... ដែលស្ម័គ្រចិត្តជួយក្នុងការអភិវឌ្ឍន៍ ជនបទ ។

មាត្រាទី ១២ . បទប្បញ្ញត្តិការងារមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ ... អនុក្រឹត្យនេះ ។

មាត្រាទី ១៣ . បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រាទី ១៤ . សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី គ្រប់ក្រសួង-ស្ថាប័ន និងអភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់តាំងពី ថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

បានជ្រាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១

សម្តេច នាយករដ្ឋមន្ត្រីទី២

សហរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទីស្តីការគណៈរដ្ឋមន្ត្រី និង

អភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

គាត ឈន់

* * *

# អនុក្រឹត្យ លេខ ០២ អនក្រ.បក

## ស្តីពីការបន្ថែមប្រាក់កំរៃគរុកោសល្យ ជូនបុគ្គលិកសិក្សា

## នៃ ក្រសួងអប់រំយុវជន និង កីឡា

* * * * * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ ន.ស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ន.ស/រ.ក.ម/១០.៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ ន.ស/រ.ក.ត/១០.៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីបង្កើតក្រសួងអប់រំយុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខន.ស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

មាត្រា ១ ._ ត្រូវបានបន្ថែមប្រាក់កំរៃគរុកោសល្យលើប្រាក់កំរៃគរុកោសល្យពីមុន ជូនបុគ្គលិកសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡាម្នាក់ខែម្នាក់ ១១.៨០០ រៀល ។

មាត្រា ២ ._ ប្រាក់ឧបត្ថម្ភបន្ថែមដែលកំណត់ក្នុងមាត្រា១ ត្រូវចាប់អនុវត្តពីថ្ងៃ ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ តទៅ ។

មាត្រា ៣ ._ សពេរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងខ្លួន ។

មាត្រា៤ ._ អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

បានយកសេចក្តីជំរាបជូនឯកឧត្តម និង សម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

* * *

www.pheakdeylaw.com